ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. ១៧៤ MOC / SM 2013

# ប្រកាស

## ស្តីពីគោលការណ៍ និងនីតិវិធីអនុវត្តពាក់ព័ន្ធនឹងការនាំចូល ការដាក់លក់លើទីផ្សារ និង ការផ្សាយពាណិជ្ជកម្ម នូវផលិតផលអគ្គិសនី និងគ្រឿងអេឡិចត្រូនិក ដែលមានបញ្ញត្តិបច្ចេកទេសគ្រប់គ្រង

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០០០ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ របស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០០៨ ស្តីពីការតំឡើងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ឲ្យទៅជាអគ្គនាយកដ្ឋានកម្ពុជា ត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល)
- ប្រកាសលេខ ១០០៣ ឧរថ.សឧក.ប្រក ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល កំណត់មុខផលិតផលដែលស្ថិតក្រោមស្តង់ដារបញ្ជា ។
- កិច្ចព្រមព្រៀងស្តីពីរបបបញ្ញត្តិស៊ីសង្វាក់គ្នាក្នុងអាស៊ានចំពោះឧបករណ៍អគ្គិសនី និងអេឡិចត្រូនិច ។
- ក្នុងគោលបំណងធ្វើឲ្យប្រសើរនូវកិច្ចការការពារអ្នកប្រើប្រាស់ទាំងក្នុងទិដ្ឋភាពសុវត្ថិភាព ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច និងទាំងកិច្ចការការពារបរិស្ថាន ព្រមទាំងធានាដល់ការធ្វើពាណិជ្ជកម្មប្រកបដោយសមធម៌ ។

# សម្រេច

**ប្រការ ១** . រាល់ការនាំចូល ការដាក់លក់លើទីផ្សារ និងការផ្សាយពាណិជ្ជកម្ម ក្នុងបំណងធ្វើការផ្គត់ផ្គង់នូវផលិតផលអគ្គិសនី និងគ្រឿងអេឡិចត្រូនិកថ្មីសំរាប់តភ្ជាប់ ឬបន្តចូលទៅនឹងចរន្តអគ្គិសនី(ចរន្ត Alternative) ឬដំណើរការដោយថាមពលអាគុយ (ចរន្តផ្ទាល់ Direct Current) ដែលមានកំលាំងជា វ៉ុលទាប (Low Voltage) ដូចមានរាយនាមក្នុងបញ្ជីជាឧបសម្ពន្ធ័ភ្ជាប់ និងដែលត្រូវមានភាពអនុលោម ត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវចាំបាច់ផ្នែកសុវត្ថិភាព អាចត្រូវបានអនុញ្ញាត្តិ លុះត្រាតែអ្នកនាំចូល ឬអ្នកផលិតបំពេញបានត្រឹមត្រូវតាមបណ្តាវិធានការ និងនីតិវិធី ដូចខាងក្រោម៖

១. ផលិតផលអគ្គិសនី និងគ្រឿងអេឡិចត្រូនិច នាំចូលសម្រាប់ការធ្វើពាណិជ្ជកម្មដំបូង ត្រូវចុះបញ្ជីនៅអគ្គនាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម ដោយផ្អែកលើមូលដ្ឋាននៃវិញ្ញាបនប័ត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវ១១៣បេ)
ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៦៦ ០៨៨/៨៦៦ ៨៧៨
ទូរសារលេខ: (៨៥៥) ២៣ ៨៦៦ ៨២៥
អ៊ីម៉ែល: moccab@moc.gov.kh

បញ្ជាក់ភាពអនុលោមតាមលក្ខខណ្ឌតម្រូវចាំបាច់ផ្នែកសុវត្ថិភាព និងត្រូវបិទបន្ថែមនូវស្លាកសញ្ញាបញ្ជាក់បង្ហាញនូវកិច្ចចុះបញ្ជីការរបស់អគ្គនាយកដ្ឋានកាំកុងត្រូល ពេលធ្វើការផ្គត់ផ្គង់ ឬចរាចរលើទីផ្សារ ។

២. ចំពោះផលិតផលអគ្គិសនី និងគ្រឿងអេឡិចត្រូនិចដែលផលិតក្នុងស្រុក ត្រូវគោរពតាមលក្ខខណ្ឌដូចមានបញ្ជាក់ក្នុងស្តង់ដារបញ្ជារប្រកាសដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (ប្រកាសលេខ១០០៣ ឧរថ.សឧក.ប្រក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦) ។

**ប្រការ ២** . ពាក្យស្នើសុំចុះបញ្ជីការផលិតផល ត្រូវភ្ជាប់ដោយវិញ្ញាបនប័ត្របញ្ជាក់ភាពអនុលោម និងឯកសាររដ្ឋបាលចាំបាច់ កំណត់ដោយអគ្គនាយកដ្ឋានកាំកុងត្រូល ។ វិញ្ញាបនប័ត្របញ្ជាក់ភាពអនុលោមនៃលក្ខខណ្ឌតម្រូវផ្នែកសុវត្ថិភាពតាមរបបកំណត់ ត្រូវ៖

១. ចេញដោយមន្ទីរពិសោធន៍ ឬស្ថាប័នទទួលបន្ទុកធ្វើវិញ្ញាបនកម្មដែលត្រូវចុះបញ្ជីការតាមរបបទទួលស្គាល់គ្នាទៅវិញទៅមក ដោយគណៈកម្មាធិការអាស៊ានជាលក្ខណៈផ្នែកគ្រប់គ្រងផលិតផលអគ្គិសនី និងអេឡិចត្រូនិក (Joint Sectoral Committee for the ASEAN EE MRA ) ចំពោះផលិតផល ដែលផលិតក្នុងបណ្តាប្រទេសសមាជិកអាស៊ាន (Intra-ASEAN)។

២. ចេញដោយមន្ទីរពិសោធន៍ ឬស្ថាប័នទទួលបន្ទុកធ្វើវិញ្ញាបនកម្មដែលសមត្ថភាពត្រូវបានទទួលស្គាល់ជាលក្ខណៈស្តង់ដារអន្តរជាតិ ហើយដែលអ្នកនាំចូលត្រូវផ្តល់ឯកសារបញ្ជាក់ប្រភពច្បាស់លាស់ចំពោះផលិតផលដែលផលិតនៅបណ្តាប្រទេសក្រៅអាស៊ាន (Non-ASEAN) នោះ។

**ប្រការ ៣** . អ្នកនាំចូលផលិតផលដែលមានចុះបញ្ជីការរួច ត្រូវធ្វើការប្រកាសបញ្ជាក់ការនាំចូលតាមជើងនីមួយៗ មកអគ្គនាយកដ្ឋានកាំកុងត្រូល ដោយមានភ្ជាប់ឯកសារបច្ចេកទេសចាំបាច់សំរាប់ជាមូលដ្ឋានគាំទ្រដំណើរការវិភាគ វាយតម្លៃគ្រោះលើផលិតផល ដើម្បីកំណត់ប្រព្រឹត្តិកម្មជាក់លាក់ពាក់ព័ន្ធនឹងរបបនៃការត្រួតពិនិត្យ ពេលទំនិញមកដល់ សម្រួលដល់ការសំរេចបញ្ចេញទំនិញរបស់គេ ។

**ប្រការ ៤** . វិធានការកំណត់ខាងលើ មានប្រសិទ្ធិភាពអនុវត្តក្រោយរយៈពេល ៣ ខែ (បីខែ) ក្រោយថ្ងៃចុះហត្ថលេខាតទៅ។

**ប្រការ ៥** . នាយិកាខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកកាំកុងត្រូល អគ្គនាយកពាណិជ្ជកម្មអន្តរជាតិ អគ្គនាយកពាណិជ្ជកម្មក្នុងប្រទេស អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ឲ្យមានប្រសិទ្ធិភាព ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែសីហា ឆ្នាំ ២០១៣

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

ចម្លងជូន ៖

- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ **ម៉ែន សំអន**
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **គាត ឈន់**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានកាំកុងត្រូល "ដើម្បីអនុវត្ត"
- សភាពាណិជ្ជកម្មកម្ពុជា
- សភាពាណិជ្ជកម្មរាជធានីភ្នំពេញ
- អាជីវករផលិតផលអគ្គិសនី និងគ្រឿងអេឡិចត្រូនិច (អ្នកនាំចូល អ្នកលក់ដុំ) "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

តារាងនេះ ជាឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសលេខ:..១៧៥.......MOC/SM2013 ចុះថ្ងៃទី.២៨......ខែសីហា ឆ្នាំ ២០១៣

## ឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសស្តីពី

## គោលការណ៍ និងនីតិវិធីអនុវត្តពាក់ព័ន្ធនឹងការនាំចូល ការដាក់លក់លើទីផ្សារ និងការផ្សាយពាណិជ្ជកម្ម នូវផលិតផលអគ្គិសនី និងគ្រឿងអេឡិចត្រូនិកថ្មី ដែលមានបញ្ញត្តិបច្ចេកទេសគ្រប់គ្រង

### បញ្ជីផលិតផលអគ្គិសនី និងគ្រឿងអេឡិចត្រូនិក ដែលមានបញ្ញត្តិគ្រប់គ្រង

(យោង៖ប្រកាសលេខ១០០៣ ឧរថ.សឧក.ប្រក ចុះថ្ងៃទី១៣ខែកញ្ញាឆ្នាំ២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល)

| ល.រ (១) | Head (២) | Tariff-code (៣) | បរិយាយទំនិញ Description of Goods (៤) | ស្តង់ដារកម្ពុជា Cambodian Standard (៥) | ស្តង់ដារអន្តរជាតិ International Standard (៦) |
|---|---|---|---|---|---|
| 1 | 8414 | 8414.51.20 | កង្ហារអគ្គិសនីដាក់ភ្ជាប់ពិដាន និងរ៉េអូស្តា<br>Electrical ceiling fan and regulator | CS 0045:2003<br>CS 0040:2003<br>CS 0010:2003 | IEC 60335-2-80<br>IEC 60879<br>IEC 60335-1 |
| 2 | | 8414.51.90 | កង្ហារអគ្គិសនី និងរ៉េអូស្តា<br>Electrical moving-louver fan and regulator | CS 0045:2003<br>CS 0040:2003<br>CS 0010:2003 | IEC 60335-2-80<br>IEC 60879<br>IEC 60335-1 |
| 3 | | 8414.51.10 | កង្ហារអគ្គិសនីដាក់លើតុ និងរ៉េអូស្តា<br>Electric table fan and regulator | CS 0045:2003<br>CS 0040:2003<br>CS 0010:2003 | IEC 60335-2-80<br>IEC 60879<br>IEC 60335-1 |
| 4 | | 8414.51.20 | កង្ហារអគ្គិសនីដាក់ភ្ជាប់ជញ្ជាំង និងរ៉េអូស្តា<br>Electrical wall fan and regulator | CS 0045:2003<br>CS 0040:2003<br>CS 0010:2003 | IEC 60335-2-80<br>IEC 60879<br>IEC 60335-1 |
| 5 | | 8414.51.90 | កង្ហារអគ្គិសនីបក់ខ្យល់ និងរ៉េអូស្តា<br>Electric ventilating fan and regulator | CS 0045:2003<br>CS 0010:2003 | IEC 60335-2-80<br>IEC 60335-1 |
| 6 | 8418 | | ទូទឹកកក<br>Refrigerators | CS 0010:2003<br>CS 0021:2003 | IEC 60335-1<br>IEC 60335-2-24 |
| 7 | 8418 | | ទូបង្កក<br>Electric freezer | CS 0010:2003<br>CS 0021:2003 | IEC 60335-1<br>IEC 60335-2-24 |